ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ7-09-213 ប្រ.ក

# ប្រកាស

## ស្តីពី

## ការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ១៩៩៦ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញប្រកាសលេខធ ៥-៩៥-៤៧ ប្រក ចុះថ្ងៃទី១៦ ខែ មីនា ឆ្នាំ ១៩៩៥ ស្តីពីការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់
- យោងតាមសំណើរបស់អគ្គនាយកដ្ឋាន

## សំ រេ ច

**ប្រការ ១.-**

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានសិទ្ធិក្នុងការកំណត់នូវអត្រាការប្រាក់លើប្រាក់បញ្ញើ និងការផ្តល់ឥណទានជាប្រាក់រៀលនិងជារូបិយប័ណ្ណ យោងតាមលទ្ធភាព និងគោលនយោបាយអត្រាការប្រាក់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និមួយៗ។

**ប្រការ ២.-**

រាល់ដំណាច់ខែនីមួយៗ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរ ស្តីពី អត្រាការប្រាក់ជាមធ្យមដែលបានអនុវត្តលើប្រាក់បញ្ញើ និងការផ្តល់ឥណទានមកធនាគារជាតិនៃកម្ពុជា។

**ប្រការ ៣.-**

ប្រកាសលេខធ ៥-៩៥-៤៧ ប្រក ចុះថ្ងៃទី១៦ ខែ មីនា ឆ្នាំ ១៩៩៥ ស្តីពីការបើកទូលាយ ក្នុងការកំណត់អត្រាការប្រាក់ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រឹះស្ថាន ធនាគារ និងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀង១ខ្លួន ។

**ប្រការ ៥.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។៚

រាជធានីភ្នំពេញ, ថ្ងៃទី 9 ខែ កញ្ញា ឆ្នាំ ២០០៩

**ទេសាភិបាល**

**ជា_ចាន់តូ**

**កន្លែងទទួល**

- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"